ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ✓ មស.

# សារលិខិតជូនពរ

## សូមគោរពជូន
## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា
## ក្នុងឱកាសទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២១

***សម្តេចកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពដ៏ខ្ពង់ខ្ពស់!***

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ សូមចូលរួមអបអរសាទរ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១១០ នៃទិវាអន្តរជាតិនារី ០៨មីនា ឆ្នាំ២០២១នេះ ដោយក្តីសោមនស្សរីករាយ សូមគោរពជូនពរ និងបួងសួងដល់គុណព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ ដល់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា** សូមសម្តេចទទួលបាននូវប្រាជ្ញាឈ្លាសវៃ ប្រកបតែនឹងបរមសុខ សុភមង្គល ឈ្នះអស់មាសត្រូវគ្រប់ទិសទី និងវៀរចាករោគាព្យាធិគ្រប់ពេលវេលា ដើម្បីដឹកនាំស្ថាប័នកាកបាទក្រហមកម្ពុជាឆ្ពោះទៅកាន់វឌ្ឍនភាព និងទទួលបានជោគជ័យថ្មីៗបន្ថែមទៀត ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលឧត្តុង្គឧត្តមប្រពៃថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមកោតសរសើរដ៏ស្មោះចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ដែលជាកុលធីតាខ្មែរគំរូដ៏ឆ្នើម មានស្នាដៃប៉ិនប្រសប់ និងគំនិតប្រាជ្ញាឧត្តុង្គឧត្តមឈ្លាសវៃដែលបានយកអស់កម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី ធ្វើពលិកម្មមិនខ្លាចនឿយហត់គ្រប់បែបយ៉ាងដើម្បីឧត្តមប្រយោជន៍របស់ប្រទេសជាតិ ក្នុងការដឹកនាំកាកបាទក្រហមកម្ពុជាដើម្បីការងារមនុស្សធម៌ដ៏ថ្លៃថ្លាប្រកបដោយគុណធម៌ សប្បុរសធម៌ ដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋរងគ្រោះគ្រប់រូប គ្រប់ទីកន្លែង នៅទូទាំងប្រទេស និងបានខិតខំលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងតម្លៃគ្រួសារខ្មែរឱ្យបានខ្ពង់ខ្ពស់រុងរឿង ។

យើងខ្ញុំទាំងអស់គ្នា សូមឧទ្ទិសបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំង**បុត្រា-បុត្រី ចៅប្រុស-ចៅស្រី** ទាំងអស់ សូមប្រកបដោយសុខភាពមាំមួន ប្រាជ្ញាវាងវៃ និងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រពីយើងខ្ញុំ។

ថ្ងៃ សុក្រ ៧រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ-សុខា